# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

***********

# កិច្ចសន្យា
## ស្តីពី
## ការវិនិយោគទុន លើដំណាំកសិកម្ម និង កៅស៊ូ
## រវាង
## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## និង
## ក្រុមហ៊ុន CAMBO VICTOR INVESTING AND DEVELOPING Co.; LTD

******

<u>កិច្ចសន្យានេះធ្វើឡើងរវាង:</u>

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ តំណាងដោយឯកឧត្តមរដ្ឋមន្ត្រីស្តីទីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានអាស័យដ្ឋានលេខ: ២០០ មហាវិថីព្រះនរោត្តម ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣២០ មានគណនីលេខ : ០១០៦៣២២០ នៅធនាគារពាណិជ្ជកម្មក្រៅប្រទេស ហៅថា ភាគី"ក" ។

ជាមួយនិង

**ក្រុមហ៊ុន CAMBO VICTOR INVESTING AND DEVELOPING Co.; LTD** មានអាស័យដ្ឋាន ផ្ទះលេខ ២៥២ ផ្លូវលេខ ១៤៣ សង្កាត់ បឹងកេងកង ៣ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញទូរស័ព្ទលេខ (៨៥៥ ) ០១៦ ៨២៣ ០៦៨ និង ០១៥ ៩១៤ ១៦១ និង ទូរសារលេខ ០២៣ ៤២៨ ៩៥០ ដែលតំណាំងដោយ លោក WANG SHEN MING ជនជាតិ ចិន លិខិតឆ្លងដែនលេខ M 12148996 មានគណនី លេខ ៩១៨ ៥០ ០៥៦៨ នៅធនាគារ FIRST COMMERCIAL BANK ដែលមានអាស័យដ្ឋានលេខ លេខ ២៦៣ មហាវិថី ព្រះអង្គដួង សង្កាត់ វត្តភ្នំ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ហៅថាភាគី "ខ" ។

-យោងតាមខ្លឹមសារលិខិតជូនដំណឹងលេខ ១៣៦១ សជណ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០០ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី ។
-លិខិតសិទ្ធប្រទានលេខ ៥៨ សប្រទ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០០ របស់ រាជរដ្ឋាភិបាលកម្ពុជា
-ដោយផ្អែកលើច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

ភាគីទាំងពីរបានឯកភាពគ្នាលើប្រការទាំងឡាយ មានដូចខាងក្រោមនេះ :

## ប្រការ ១ : កម្មវត្ថុនៃកិច្ចសន្យា

កម្មវត្ថុនៃកិច្ចសន្យានេះគឺភាគី "ក" យល់ព្រមផ្តល់ដីសម្បទានដែលមានផ្ទៃក្រឡាសរុបចំនួន ២៦.៥៥០ ហិកតា ដែលមានទីតាំងស្ថិតនៅក្នុង ស្រុក ភ្នំស្រួច ខេត្ត កំពង់ស្ពឺ ( ដូចមានផែនទីជូនភ្ជាប់ ) ជូនទៅភាគី "ខ" កាន់កាប់ប្រើប្រាស់ធ្វើអាជីវកម្មផលិតកម្មកសិកម្ម ។ ទំហំផ្ទៃដីនេះបានបញ្ជាក់កាន់ តែច្បាស់ ក្នុងផែនទីចង្អុលទីតាំងដែលភ្ជាប់ជាមួយឧបសម្ព័ន្ធនៃកិច្ចសន្យានេះដែលចាប់ពីពេលនេះតទៅហៅថា " ទីតាំង " ហើយមានអរដោនេដូចខាងក្រោម :

A: 20 – 49,8 ; B : 23,5 – 51,8<br>
C: 23,5 – 91 ; D : 15 – 91<br>
E: 15 – 66 ; F : 20 – 66

ផ្ទៃដីសរុបចំនួន ២៦.៥៥០ ហិកតា ខាងលើនេះមាន :

១.១ ដីដែលភាគី "ខ" អាចធ្វើអាជីវកម្មដោយផ្ទាល់

១.២ ដីជាកម្មសិទ្ធិរបស់ពលរដ្ឋកាន់កាប់ដោយស្របច្បាប់ដីមួយចំនួនទៀតជិតៗភូមិ សំរាប់ប្រជាជន ធ្វើការ អភិវឌ្ឍន៍ ដែលត្រូវកាត់ចេញ ឬ ក្រុមហ៊ុនអាចសហការធ្វើអាជីវកម្មជាមួយពលរដ្ឋដោយមានការយល់ព្រមទាំងសងខាង។ ក្នុងករណីមានការរំលោភកាន់កាប់ដីសម្បទាននេះដោយខុសច្បាប់ ភាគី "ខ" មានសិទ្ធប្តឹងតវ៉ាទៅស្ថាប័នមានសមត្ថកិច្ច ។

១.៣ ដីភ្នំ - ដីអាងទឹក ដីព្រៃផ្តល់ផល ដីព្រៃការពារ និង តំបន់ការពារធម្មជាតិផ្សេង ៗ ទៀតត្រូវរក្សាទុកអោយស្ថិតនៅជាលក្ខណៈធម្មជាតិ។

១.៤ ចំនួនផ្ទៃដីដែលមានចែងក្នុងចំនុច ១.១ , ១.២ , ១.៣ ភាគី "ក" និង ភាគី "ខ" ត្រូវសហការ និង ស្ថាប័នមានសមត្ថកិច្ចសិក្សាស្រាវជ្រាវអង្កេត និងកំណត់ទីតាំងផ្ទៃដីពាក់ពន្ធ័អោយបានចប់សព្វគ្រប់ក្នុងរយៈពេល ០៦ ខែ បន្ទាប់ពីកិច្ចសន្យាត្រូវបានចុះហត្ថលេខា ហើយត្រូវកាត់ចេញផ្ទៃដីពាក់ព័ន្ធទាំងអស់នេះចេញពីគំរោងវិនិយោគរបស់ខ្លួន។ រាល់ការចំណាយលើការអង្កេតនេះជាបន្ទុករបស់ ភាគី "ខ" ។

## ប្រការ ២ : អំពីថេរៈវេលា

២.១ កិច្ចសន្យានេះមានរយៈពេល ៧០ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានៃកិច្ចសន្យានេះតទៅ ។ នៅពេលផុតរយៈពេលនៃកិច្ចសន្យា ភាគី " ខ " ត្រូវប្រគល់ទីតាំង និង ទ្រព្យសម្បត្តិទាំងអស់ដូចជា : ដំណាំ , សំណង់អាគារ , រោងចក្រ សំភារៈបរិក្ខាផ្សេងៗនិងធនធានធម្មជាតិទាំងអស់ជូនភាគី ក វិញ ។

២.២ រយៈពេល ០១ ឆ្នាំ មុនពេលផុតកំណត់កិច្ចសន្យា ភាគី "ខ" អាចសុំជួលទីតាំងធ្វើវិនិយោគបន្តទៅទៀត ។ ការបន្តអាចធ្វើឡើងបានក្នុងករណីមានគោលការណ៍អនុញ្ញាតិពីរាជរដ្ឋាភិបាលដោយយោលទៅតាមការអនុវត្ត កន្លងមករបស់ភាគី "ខ" គោលនយោបាយរបស់រាជរដ្ឋាភិបាលនៅពេលនោះនឹងមាន ការពិភាក្សាដោយមានការឯកភាពពី ភាគី "ក" ដែលជាលក្ខខណ្ឌសំរាប់កិច្ចសន្យាថ្មី ។

## ប្រការ៣ : គោលដៅ និង កម្មវិធីប្រើប្រាស់

គោលដៅ និង កម្មវិធីប្រើប្រាស់ទីតាំងរបស់ភាគី "ខ" គឺការធ្វើផលិតកម្មអាជីវកម្ម ដោយផ្អែកតាមរបាយការណ៍បច្ចេកទេស-សេដ្ឋកិច្ចភ្ជាប់ជាឧបសម្ព័ន្ធ ដែលក្នុងនោះមានគោលសំខាន់ៗដូចតទៅ :

៣.១ គោលដៅផលិតកម្ម-អាជីវកម្ម :

៣.១.១ ផលិតកម្មចំបង : សណ្តែកដី , ពោត និង ដំឡូងមី

៣.១.២ ផលិតកម្មបន្ទាប់បន្សំ : សណ្តែកសៀង , ស្រូវ , ដំណាំហូបផ្លែ និង ចិញ្ចឹមសត្វ

៣.១៣ ការសាងសង់ : សំណង់អាគារ រោងចក្រកែច្នៃ និង មន្ទីរស្រាវជ្រាវបច្ចេកទេសដាំដុះ

៣.១.៤ ភាគី "ខ" មានសិទ្ធសុំកែប្រែមុខដំណាំដូចមានចែងក្នុងចំនុច ៣.១.១ និង ៣.១.២ ខាងលើមកភាគី "ក"

៣.២ កម្មវិធីប្រើប្រាស់ទីតាំង : ភាគី "ខ" ត្រូវប្រើផ្ទៃដីដែលបានរៀបរាប់ក្នុងប្រការ ១.១ នៃ កិច្ចសន្យានេះ ក្នុងរយៈពេល ១៥ ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យានេះ តាមផែនការ ដូចខាងក្រោម :

| | |
|---|---|
| ឆ្នាំទី១ : | ១ % ហិកតា |
| ឆ្នាំទី២ : | ៣ % ហិកតា |
| ឆ្នាំទី៣ : | ៥ % ហិកតា |
| ឆ្នាំទី៤ : | ៧ % ហិកតា |
| ឆ្នាំទី៥ : | ៩ % ហិកតា |
| ឆ្នាំទី៦ : | ៧.៥ % ហិកតា |
| ឆ្នាំទី៧ : | ៧.៥ % ហិកតា |
| ឆ្នាំទី៨ : | ៧.៥ % ហិកតា |
| ឆ្នាំទី៩ : | ៧.៥ % ហិកតា |
| ឆ្នាំទី១០ : | ៧.៥ % ហិកតា |
| ឆ្នាំទី១១ : | ៧.៥ % ហិកតា |
| ឆ្នាំទី១២ : | ៧.៥ % ហិកតា |
| ឆ្នាំទី១៣ : | ៧.៥ % ហិកតា |

ឆ្នាំទី១៤ : ៧.៥ ٪ ហិកតា

ឆ្នាំទី១៥ : ៧.៥ ٪ ហិកតា

## ប្រការ ៤ : អំពីប្រាក់កក់ និង ថ្លៃឈ្នួល

៤.១ ប្រាក់កក់: ភាគី "ខ" ត្រូវបង់ប្រាក់កក់ចំនួនស្មើ ១ USD (មួយដុល្លាសហរដ្ឋអាមេរិក) ក្នុងមួយហិកតា សំរាប់ធានាការអនុវត្តន៍កិច្ចសន្យានេះ។ ប្រាក់កក់នេះ ត្រូវបង់តាមចំនួនផ្ទៃដីនៅសល់ជាក់ស្តែង យ៉ាងយឺតបំផុតរយៈពេល ០៣ខែ ក្រោយពីថ្ងៃចុះហត្ថលេខានៃកិច្ចសន្យា ។ ប្រាក់កក់នេះត្រូវបង្វិលសងវិញនៅពេលដែលភាគី "ខ"អនុវត្តន៍ការដាំដុះចប់តាមគំរោងក្នុងប្រការ ៣ ។

៤.២ ភាគី "ខ" ត្រូវបង់ថ្លៃឈ្នួលដីប្រចាំឆ្នាំតាមអត្រាថ្លៃឈ្នួលដីសម្បទាននឹងតាមរបបរដ្ឋកំណត់។ ប្រាក់ឈ្នួលត្រូវបង់ជាប្រចាំឆ្នាំនៅរៀងរាល់ខែមករា ហើយត្រូវបងយ៉ាងយឺតអោយបានមុនថ្ងៃទី ៣១ ខែ មករា នៃឆ្នាំនិមួយ១ ។

៤.៣ ភាគី "ខ"យល់ព្រមបង់ថ្លៃឈ្នួលដីសម្បទានទៅតាមអត្រាប្រែប្រួល ដែលសំរេចដោយរាជរដ្ឋាភិបាល។

៤.៤ ក្នុងករណីមានការយឺតយ៉ាវក្នុងការបង់ប្រាក់ឈ្នួលតាមការកំណត់ដូចមានចែងក្នុងប្រការ ៤.២ ភាគី "ខ" ត្រូវទទួលពិន័យចំនួន ២% ក្នុងមួយខែ លើទឹកប្រាក់ឈ្នួលប្រចាំឆ្នាំនិមួយ ១ តាមចំនួនខែដែលយឺតយ៉ាវ ។ ការខកខានមិន បានបង់ប្រាក់ឈ្នួលទាំងស្រុងក្នុងរយៈពេលមួយឆ្នាំឡើងទៅក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា គាភី "ក" មានសិទ្ធរឹបអូសប្រាក់កក់ និង ដីសម្បទានព្រមទាំងដំណាំទាំងអស់ទុកជាសម្បត្តិរដ្ឋព្រមទាំងបញ្ឈប់កិច្ចសន្យា ដោយមិន ចេញសោហ៊ុយទូទាត់រាល់ការចំណាយរបស់ភាគី "ខ" ដែលអនុវត្ត កន្លង មក ។

៤.៥ ប្រាក់ថ្លៃឈ្នួលដី និងប្រាក់កក់ធានាការអនុវត្តន៍កិច្ចសន្យាក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទជាអ្នកកំណត់ថ្ងៃដែលត្រូវបង់រួចភាគី "ខ" ទៅបង់ចូលថវិការដ្ឋនៅរតនាគាជាតិ - គណនី របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

៤.៦ ភាគី "ខ" ត្រូវមានកាតព្វកិច្ចបង់ពន្ធផ្សេង ១ ទៀតជូនរដ្ឋតាមច្បាប់ជាធរមាន ។

## ប្រការ ៥ : ការផ្ទេរសិទ្ធិ ការជួលបន្ត ឬ ការលក់កិច្ចសន្យា

៥.១ ភាគី "ខ" អាចផ្ទេរសិទ្ធិទៅអោយឧត្តរាធិការីរបស់ខ្លួនបាន ។ ដែលហៅថាឧត្តរាធិការីស្របច្បាប់គឺជាបុគ្គលទាំងឡាយណាដែលភាគី "ខ" ប្រគល់អោយស្នងកេរមរតករបស់ខ្លួននៅចំពោះមុខច្បាប់ ។ ការប្រកាសជូនដំណឹងស្តីពីការ ផ្ទេរសិទ្ធ ឬសំរេចណាមួយទៅអោយឧត្តរាធិការីជន ត្រូវជូនដំណឹងមកភាគី "ក" យ៉ាងតិច ០៦ ខែ មុនពេលចាប់ផ្តើមអនុវត្ត។

៥.២ ភាគី "ខ" ក្រោមសិទ្ធិទទួលខុសត្រូវរបស់ខ្លួនចំពោះមុខច្បាប់និងកិច្ចសន្យានេះអាចសហការជាមួយ ក្រុមហ៊ុនដៃគូរបស់ខ្លួនបានដើម្បីអភិវឌ្ឍន៍ផលិតកម្ម-អាជីវកម្មដែលស្ថិតនៅក្នុងក្របខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យានេះ ។

៥.៣ ក្នុងករណីនេះភាគី "ខ" ជួលបន្ត ឬ លក់កិច្ចសន្យានេះ ភាគី "ខ" ត្រូវអនុវត្តតាមច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និង មានការយល់ព្រមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមសំណើរបស់ភាគី "ក" ។

៥.៤ ដើម្បីរកទុនពីធានាគារក្នុង និង ក្រៅប្រទេសមកពង្រីកការវិនិយោគទុនបន្ថែមភាគី "ខ" មានសិទ្ធិយកដំណាំ និង ទ្រព្យសម្បត្តិដែលបានចំណាយទុនវិនិយោគកន្លងមកនៅលើដីសម្បទាននោះសំរាប់យកទៅធានាបំណុល ដោយមានការជួយគាំទ្រពីភាគី "ក" ។

## ប្រការ ៦ : សិទ្ធិ និង ភារកិច្ចរបស់ភាគី "ក"

ភាគី "ក" មានសិទ្ធិ និង ភារកិច្ចដូចខាងក្រោម:

៦.១ ជួយអន្តរាគមន៍ទៅស្ថាប័នដែលពាក់ព័ន្ធដើម្បីដោះស្រាយឧប្បត្តិហេតុណាមួយដែលមានអ្នកប្រព្រឹត្តបទល្មើសរំលោភលើសិទ្ធិរបស់ភាគី "ខ" ក្នុងក្របខ័ណ្ឌកិច្ចសន្យានេះក្នុងការអភិវឌ្ឍន៍ និង ការប្រើប្រាស់ទីតាំង ឬ រឹបអូសយកផ្នែកណាមួយនៃទីតាំង ។

៦.២ តាមដានត្រួតពិនិត្យលើ :

- ការអនុវត្តន៍កិច្ចសន្យា
- ផលប៉ះពាល់លើបរិស្ថាន
- ការងារបច្ចេកទេស និង កម្មវិធីផលិតកម្ម-អាជីវកម្ម

## ប្រការ ៧ : សិទ្ធិ និង ភារកិច្ចរបស់ភាគី "ខ"

ភាគី "ខ" មានសិទ្ធិ និង ភារកិច្ចដូចខាងក្រោម :

៧.១ យល់ព្រមបង់ប្រាក់កក់ និង ថ្លៃឈ្នួលត្រឹមត្រូវតាមប្រការ ៤ នៃកិច្ចសន្យានេះរហូតដល់ពេលចប់អាណត្តិកិច្ចសន្យា ។

៧.២ ភាគី "ខ" យល់ព្រមទទួលបន្ទុកចំណាយលើការអង្កេតសិក្សាដូចមានចែងក្នុងប្រការ ១.៤ ។

៧.៣ ភាគី "ខ" ត្រូវធ្វើផែនការគ្រប់គ្រង និង អភិវឌ្ឍន៍នៃទីតាំងជូនក្រសួងកសិកម្មរុក្ខាប្រមាញ់និង នេសាទ អោយបានយ៉ាងយឺត ០៩ ខែ ក្រោយពីចុះកិច្ចសន្យា ។ ផែនការគ្រប់គ្រងនេះត្រូវមានផែនការមេនៃការប្រើប្រាស់ទីតាំង ( សំណង់ផ្សេងៗ ហេដ្ឋារចនាសម្ព័ន្ធ-ឡូត៍ផ្សេងៗនៃដីដាំដុះ ។ ល។ ) រួមនិងផែនការអភិវឌ្ឍន៍ - យុទ្ធសាស្ត្រ កម្មវិធី និង ការប្រើប្រាស់បច្ចេកទេសផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍន៍រយៈពេលវែង ( រយៈ

ពេលផ្តើមដំណើរការរហូតការប្រើប្រាស់អស់ដីទីតាំង និង រយៈពេលបន្ត ) ។ ភាគី "ខ" អាចចុះដំណើរការងារបានលុះត្រាតែមានការយល់ព្រមលើឯកសារផែនការគ្រប់គ្រង់ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

៧.៤ មានសិទ្ធិជ្រើសរើសពលកម្មក្នុងស្រុកឬ ជួលអ្នកឯកទេសបរទេសដើម្បីជួយណែនាំឬបង្ហាត់ បង្ហាញអំពីការងារបច្ចេកទេសអាជីវកម្មផលិតកម្មតាមសេចក្តីត្រូវការចាំបាច់របស់ខ្លួនក្នុងករណីគ្មានអ្នកឯកទេសនៅក្នុងប្រទេស ដោយគោរពតាមច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា ។

៧.៥ យកចិត្តទុកដាក់ចំពោះជីវភាពរស់នៅក៏ដូចជាសុខភាព និង ការអប់រំដល់បុគ្គលិក កម្មករ និងនិងគ្រួសាររបស់គេ ដោយខិតខំកសាង លំនៅដ្ឋាន មន្ទីរពេទ្យ វត្តអារាម សាលារៀន មណ្ឌលកំសាន្តលំហែកាយ ។ល។ ដោយផ្អែកតាមលទ្ធភាពរបស់ក្រុមហ៊ុន ។

៧.៦ អនុវត្តការងារអាជីវកម្មតាមគំរោងផែនការដូចជា : ការកាប់ឆ្ការព្រៃ ការធ្វើផ្លូវ ការដាំដុះនិងថែទាំ ។ល។ ដោយគោរពលក្ខខ័ណ្ឌនិរន្តរភាព របស់ទីតាំង និងផលប៉ះពាល់លើបរិស្ថានដែលបណ្តាលមកពីការធ្វើអាជីវកម្ម-ផលិតកម្ម។

៧.៧ រៀបចំធ្វើផលិតកម្ម-អាជីវកម្មតាមផែនការដូចមានចែងក្នុងរបាយការណ៍បច្ចេកទេស-សេដ្ឋកិច្ចរបស់ខ្លួននិងដូចក្នុងប្រការ ៣ និង ប្រការ ៧.៣នៃកិច្ចសន្យានេះនៅលើផ្ទៃដីដែលរដ្ឋប្រគល់ជូន ។

៧.៨ មានសិទ្ធិលក់ដូរប្រមូលទិញបែងចែកចរាចរផលិតផលគ្រប់ប្រភេទទាំងនៅក្នុង និង ក្រៅប្រទេស តាមគោលការណ៍រដ្ឋជាធរមាន ។

៧.៩ ចំពោះការនាំចូលទុក្ខសំភារៈគ្រឿងចក្រ គ្រឿងបន្លាស់ វត្ថុធាតុគីមី ដែលបំរើអោយការធ្វើផលិតកម្ម-អាជីវកម្ម ពាក់ពន្ធ័និងការបង់ពន្ធអាករផ្សេងៗ គឺអាស្រ័យដោយច្បាប់ របស់ព្រះរាជាណាចក្រកម្ពុជាកំណត់ ។

៧.១០ ត្រូវអនុញ្ញាតអោយភាគី "ក" និង ស្ថាប័នពាក់ព័ន្ធ តាមដាន ត្រួតពិនិត្យវាយតំលៃ អំពីផលប៉ះពាល់បរិស្ថាន ។ ត្រូវអនុវត្តតាមការណែនាំរបស់ភាគី "ក" និង ស្ថាប័នពាក់ព័ន្ធក្នុងកិច្ចការពារបរិស្ថាន ។

## ប្រការ ៨ : ការអនុញ្ញាតិអោយសាងសង់

៨.១ តាមរយៈនេះភាគី "ខ" ត្រូវបានអនុញ្ញាតិអោយអនុវត្តរាល់កិច្ចការសំណង់លើទីតាំងដែលស្របតាមច្បាប់ជាធរមាន នៃ ព្រះរាជាណាចក្រកម្ពុជា និងសមស្រប នឹង ទិសដៅការងារក្នុងប្រការ ៣ នៃកិច្ចសន្យានេះ ។

៨.២ រាល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដូចជា ទំនប់ ប្រឡាយ ដែលអាចអោយមានផលប៉ះពាល់ដល់ តំបន់ជុំវិញ ត្រូវមានការអនុញ្ញាតិពីភាគី "ក" ឬស្ថាប័នពាក់ព័ន្ធ ។

## ប្រការ ៩ : សិទ្ធិនៃការគ្រប់គ្រង

រាល់អចលនៈទ្រព្យ និង ហេដ្ឋារចនាសម្ព័ន្ធព្រមទាំងសមិទ្ធិផលទាំងអស់ដែលបង្កើតឡើងដោយ ភាគី "ខ" ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគី "ខ" រហូតដុតរយៈពេលនៃកិច្ចសន្យា ។

## ប្រការ ១០ : ការបញ្ចប់កិច្ចសន្យា

១០.១ ភាគី "ខ" មានសិទ្ធិដកហូតចេញពីគំរោងការងារទាំងមូល ឬផ្នែកណាមួយក្នុងលក្ខខ័ណ្ឌមិនអាចគ្រប់គ្រង បាន និងត្រូវមានការឯកភាពពីភាគីទាំងសងខាង ។រដ្ឋាភិបាលធានានូវការវិលត្រឡប់ប្រកបដោយសុវត្ថិភាពបុគ្គលិក បរទេសរបស់ក្រុមហ៊ុន និង ក្រុមគ្រួសាររបស់ពួកគេហើយការដកត្រឡប់ទៅវិញ ឬ ការលក់សំភារៈបរិក្ខារោង ចក្រនានា នាវាដាក់ម៉ាស៊ីន នាវាផ្ទុកទំនិញ យានយន្តផ្សេង ។ ទៀត និង ប្រដាប់ប្រដារព្រមទាំង មធ្យោបាយ ដឹកជញ្ជូន ផ្សេង ។ ទៀតគ្រឿងដាក់ភ្ជាប់នៅមួយកន្លែងត្រូវធ្វើទៅតាមច្បាប់ និង បទបញ្ញត្តិជាធរមាន ។

១០.២ ក្នុងករណីដែលភាគី "ខ" ដកខ្លួនដោយខ្លួនឯងនោះ ភាគី "ខ" ត្រូវទទួលខុសត្រូវតាមមាត្រាទី ២៣ នៃ ច្បាប់ វិនិយោគ ។

១០.៣ ក្នុងករណីដែលភាគី "ខ" មិនបានចាប់ផ្តើមអនុវត្តនូវសកម្មភាពតាមដូចប្រការចែងក្នុងកិច្ចសន្យានេះក្នុងរយៈពេល ០១ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះ រដ្ឋាភិបាលមានសិទ្ធិបញ្ឈប់ កិច្ចសន្យា ដោយគ្មានលក្ខខ័ណ្ឌនិង គ្មានការសង នូវការខាតបង់ឡើយ ។ ការបញ្ឈប់បែបនេះនឹងនាំអោយមានការរឹបអូសប្រាក់កក់របស់ ភាគី "ខ" ជាសម្បត្តិរដ្ឋ ។

១០.៤ ប្រសិនបើភាគី "ខ" មិនអនុវត្តពេញលេញនូវលក្ខខ័ណ្ឌណាមួយនៃកិច្ចសន្យានេះឬសេចក្តីសំរេចនានានៃច្បាប់របស់ ព្រះរាជាណាចក្រកម្ពុជារដ្ឋាភិបាលមានសិទ្ធិបញ្ចប់កិច្ចសន្យានេះដោយគ្មានលក្ខ័ណ្ឌនិងមិនសងការខាតបង់ ។ ការបញ្ចប់បែបនេះនឹងនាំអោយមាន ការរឹបអូសប្រាក់កក់របស់ ភាគី "ខ" ជា សម្បត្តិរដ្ឋ ។

## ប្រការ ១១ : វិវាទ និង ការដោះស្រាយ (អាជ្ញាកណ្តាល )

១១.១ ក្នុងករណីដែលមានវិវាទកើតក្នុងរយៈពេលនៃការអនុវត្តន៏កិច្ចសន្យានេះភាគីទាំងពីរ នឹងសំរបសំរួលដោះស្រាយ ដោយយោលទៅតាមសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីនីមួយៗដែលមានចែងក្នុងកិច្ចសន្យានេះ ។

១១.២ ក្នុងករណីដែលភាគីទាំងពីរមិនអាចសំរបសំរួល ឬ ដោះស្រាយវិវាទនេះបានក្នុងរយៈពេល ៦០ថ្ងៃ វិវាទនេះត្រូវ ដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជួយសំរួល និង ដោះស្រាយ ។

១១.៣ ភាគីទាំងពីរឯកភាពគ្នាដោះស្រាយនូវភាពមិនចុះសំរុងគ្នាដោយលក្ខណៈជាមិត្តភាពនៅក្នុងប្រទេសកម្ពុជា ។ ក្នុង ករណីដែលភាពមិនចុះសំរុងគ្នាមិនអាចដោះស្រាយបានភាគីទាំងពីរប្រគល់អោយទៅ សាលាជំរះក្តីកណ្តាលផ្នែក ពាណិជ្ជកម្ម រឺសាលាកាត់ក្តីដទៃទៀតដែលមានសមត្ថកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប្រសិនបើពុំអាច ដោះ ស្រាយបានក្នុងប្រទេសភាគីទាំងពីរយល់ព្រមប្រគល់ការដោះស្រាយទៅអោយអាជ្ញាកណ្តាលតុលាការ នៅប្រទេស



(7)

សិង្ហបូរីដោយយោងទៅតាមបទបញ្ញត្តិកាត់ក្តីដោយអាជ្ញាកណ្តាលអន្តរជាតិនៅប្រទេសសិង្ហបូរី ។ ភាសាដែលប្រើសំរាប់អាជ្ញាកណ្តាលគឺភាសាខ្មែរនិង អង់គ្លេស ។ ភាគីទាំងពីរត្រូវទទួលខុសត្រូវរៀង១ ខ្លួនលើការបកប្រែ ។

## ប្រការ ១២ : ការទុកជាមិនបានការភាគខ្លះ

ប្រសិនបើលក្ខខ័ណ្ឌណាមួយនៃកិច្ចសន្យានេះត្រូវទុកជាមិនបានការ ឬគ្មានប្រសិទ្ធភាពផ្នែកដទៃទៀតដែលនៅសល់ត្រូវមានសុពលភាព ដូចដែលមានសរសេរជាលាយលក្ខ័អក្សរចំពោះវិសាលភាពទាំងអស់ដែលច្បាប់បានអនុញ្ញាត ។

## ប្រការ ១៣ : ច្បាប់អភិបាល

ការព្រមព្រៀងនៃកិច្ចសន្យានេះ ត្រូវគ្រប់គ្រងដោយច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ១៤ : ការព្រមព្រៀងទាំងស្រុង

ឯកសារនេះមានការព្រមព្រៀងទាំងស្រុងដោយភាគីទាំងពីរហើយបដិសេធចោលនូវការប្រាស្រ័យ ទាក់ទងការតំណាង និងការព្រមព្រៀងទាំងអស់ដែលមានពីមុនមកមិនថាឡើយដោយមាត់ ឬ ដោយសរសេរជាលាយល័ក្ខអក្សរដែលជាប់ទាក់ទិននិងកិច្ចសន្យានោះឡើយ ។ កិច្ចសន្យានេះមិនអាចកែប្រែ ឬ ផ្លាស់ប្តូរបានទេ លើកលែងតែមានសរសេរជា លាយល័ក្ខអក្សរដោយមានចុះហត្ថលេខា និង ទទួលស្គាល់ដោយភាគីទាំងពីរ ។

## ប្រការ ១៥ : ករណីប្រធានសក្តិ

ក្នុងព្រឹត្តិការណ៍ដែលភាគីទាំងពីរមិនអាចបំពេញករណីកិច្ចរបស់ខ្លួនជាផ្នែក ឬ ទាំងស្រុងបានអនុលោមទៅតាម លក្ខខ័ណ្ឌផ្សេង ១ នៃកិច្ចសន្យានេះដោយសារតែករណីប្រធានសក្តិ ភាគី "ខ" ត្រូវប្រកាសប្រាប់ ភាគី "ក" ដោយសរសេរជាលាយលក្ខ័អក្សរបញ្ជាក់ពីហេតុផលរបស់ខ្លួន ហើយកាតព្វកិច្ចរបស់ភាគី "ខ" នឹងត្រូវបញ្ឈប់ជាបណ្តោះអាសន្នក្នុងកំឡុងពេលនៃរយៈពេលដែលជាប់ពាក់ព័ន្ធនោះ ។

ពាក្យៈ " ករណីប្រធានសក្តិ " រួមមានភ្លើងឆេះ ទឹកជំនន់ ខ្យល់ព្យុះ សង្គ្រាម រញ្ជួយផែនដី ការរំជើបរំជួលនៃផ្នែកស៊ីវិល សកម្មភាពការបះបោរ កុប្បកម្ម ការផ្ទុះផ្សេង ១ ការឆ្លងរាលដាលនៃជំងឺផ្សេង១ ព្រមទាំងព្រឹត្តិការណ៍ ឬ កាលៈទេសៈផ្សេង ១ ទៀតដែលហួស ពីការគ្រប់គ្រងសមស្របរបស់ភាគីទាំងពីរ ។

## ប្រការ ១៦ : សិទ្ធិលើធនធានធម្មជាតិ និង កេរដំណែល

១៦.១ មុនពេលរានដីសំរាប់អភិវឌ្ឍន៍ ភាគី " ខ " ត្រូវសុំការយល់ព្រមពីភាគី " ក " ក្នុងការកាប់រំលើរកៃច្ឆៃ និង ដឹកជញ្ជូនឈើដែលមានលើដីនោះនិង ត្រូវបង់ថ្លៃឈើជូនភាគី "ក" ដោយផ្អែកតាមគោលការណ៍ និង ច្បាប់គ្រប់គ្រង ព្រៃឈើជាធរមាន ។

CAMBO VALLEY INVESTING ... CO.,LTD

១៦.២ នៅក្នុងការកាប់គាស់ដីសំរាប់ធ្វើផលិតកម្ម-អាជីវកម្មប្រសិនបើភាគី "ខ" រកឃើញ រ៉ែត្បូង មាស ឬវត្ថុដែលជាកេរដំណែលផ្សេងៗ របស់ជាតិនៅលើដី ឬ ក្រោមដី ត្រូវទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

## ប្រការ ១៧ : ភាសា

កិច្ចសន្យានេះធ្វើនៅរាជធានីភ្នំពេញ ជាពីរភាសា គឺភាសាខ្មែរ និង ភាសាអង់គ្លេសចំនួន ១៥ច្បាប់ ច្បាប់និមួយៗមានតំលៃស្មើៗគ្នា ។ ក្នុងការខ្វែងមតិគ្នាលើការបកស្រាយកិច្ចសន្យា ត្រូវយកភាសាខ្មែរ ជាមូលដ្ឋាន ។

## ប្រការ ១៨ : ការចាប់ផ្តើម និង បញ្ចប់

កិច្ចសន្យានេះត្រូវបានចូលជាធរមានចាប់ពីថ្ងៃទី..13..ខែ..សីហា..ឆ្នាំ ២០០១ហើយត្រូវផុតកំណត់នៅ ថ្ងៃទី..13..ខែ..សីហា....ឆ្នាំ ២០៧១ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី..13..ខែ..សីហា..ឆ្នាំ ២០០១

| តំណាងភាគី "ខ" | តំណាងភាគី "ក" |
| --- | --- |
| | រដ្ឋមន្ត្រីស្តីទី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| WANG SHEN MING | ចន្ទ សារុន<br>វិស្វករកសិកម្ម |

<u>កន្លែងទទួលឯកសារ :</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងផែនការ

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងយុត្តិធម៌

- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី

-ក្រសួងឧស្សាហ៍កម្ម រ៉ែ និង ថាមពល

-ក្រសួងបរិស្ថាន

-សាលាខេត្តកំពង់ស្ពឺ

-មន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ខេត្តកំពង់ស្ពឺ

-ភាគី "ក"

-ភាគី "ខ"

-កាលប្បវត្តិ-ឯកសារ